ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រះសីហនុ**

សំណុំរឿងរដ្ឋប្បវេណីលេខ ៣០៣

ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២

សាលក្រមរដ្ឋប្បវេណីលេខ ៣៤/០៥ "ក" រ.វ

ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ

**សាលក្រមចំពោះមុខដើមចោទ និងកំបាំងមុខសហចុងចម្លើយ**

កាលបរិច្ឆេទ នៃការបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃប្រកាសសាលក្រមនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ នៅសាលាដំបូងខេត្តព្រះសីហនុ ។

**កម្មវត្ថុបណ្តឹង:** ប្តឹងសុំឱ្យចុងចម្លើយប្រគល់ប្រាក់ ។

## សមាសភាពជំនុំជម្រះ

**- ឯកឧត្តម [redacted] ជាចៅក្រមជំនុំជម្រះ**

**- លោកស្រី [redacted] ជាក្រឡាបញ្ជីសវនាការ**

១- **ភាគី ៖**

១.១. ដើមចោទ **ក្រុមហ៊ុន** [redacted] ដែលមានអ្នកតំណាងឈ្មោះ [redacted] CHENG HUNG កើតឆ្នាំ ១៩៥៤ ជនជាតិចិន កាន់លិខិតឆ្លងដែនសញ្ជាតិតៃវ៉ាន់ លេខ [redacted] មានអាសយដ្ឋានស្ថិត [redacted] ។

-ដោយមានលោកមេធាវី [redacted] អត្តលេខ [redacted] មាន ការិយាល័យអគារ [redacted] ភ្នំពេញ និងមេធាវី [redacted] អត្តលេខ [redacted] មានការិយាល័យ ក្រុមមេធាវី [redacted] មានទីតាំង ស្ថិតនៅផ្ទះលេខ [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ។

១.២. ចុងចម្លើយ **ក្រុមហ៊ុន** [redacted] ដែលមានអ្នកតំណាងឈ្មោះ [redacted] CHANGBIN ភេទប្រុស ជនជាតិចិន កាន់លិខិតឆ្លងដែនសញ្ជាតិចិន E93905933 និងឈ្មោះ [redacted] YANRONG មានអាសយដ្ឋានស្ថិតនៅ [redacted] ។

២ - **ខ្លឹមសារសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖**

២.១. បង្គាប់អោយសហចុងចម្លើយប្រគល់ប្រាក់ដែលមិនទាន់បានបង់ចំនួន៖ **$៣៦០,០០០** **(សាមសិបប្រាំមួយម៉ឺនដុល្លារអាមេរិក)** មកអោយដើមចោទ។





Scanned with CamScanner

២.២. បង្គាប់អោយសហចុងចម្លើយសងសំណងជំងឺចិត្ត និងការខាតបង់ពេលវេលា សរុបចំនួន: **$៥០០,០០០** (ហាសិបម៉ឺនដុល្លារអាមេរិក) អោយមកដើមចោទ។

២.៣. សុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន ត្រង់ចំណុចទី១ ។

២.៤. បង្គាប់អោយសហចុងចម្លើយជាអ្នកទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តី ។

## ៣. <u>**ការពន្យល់រឿងក្តីត្រួសៗ**</u>

### ៣.១. **អង្គហេតុដែលអះអាងដោយដើមចោទ៖**

ក្នុងអំឡុងឆ្នាំ២០១៩ ចុងចម្លើយបានទាក់ទងដើមចោទឱ្យធ្វើទីលានចុះចតឧទ្ធម្ភាគចក្រ នៅខាងក្រោយសណ្ឋាគារស៊ី [redacted]។ ក្រោយពីបានពិភាក្សាគ្នារួចមក ដើមចោទក៏បានយល់ព្រមទទួលម៉ៅការក្នុងការសាងសង់ទីលានចុះចតឧទ្ធម្ភាគចក្រនោះ ដូចមានក្នុងកិច្ចសន្យាសាងសង់ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។ ក្នុងគម្រោងសាងសង់នោះទៀតសោតគឺត្រូវចំណាយអស់ទឹកប្រាក់អស់សរុបចំនួន: **២០១,០០៧.៦២ដុល្លារ (ម្ភៃម៉ឺនមួយពាន់ប្រាំពីរដុល្លារអាមេរិក និងហុកសិបពីរសេន)** ដោយត្រូវបង់ជាដំណាក់កាលមកអោយដើមចោទ ដូចមានចែងចំណុចទី០៧(ប្រាំ) នៃកិច្ចសន្យាសាងសង់ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។ ក្រោយមក ដោយឃើញពីសមត្ថភាពការងាររបស់ដើមចោទធ្វើបានយ៉ាងល្អប្រសើរ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៩ ចុងចម្លើយ ក៏បានបន្ថែមការងារឱ្យដើមចោទមួយទៀត គឺធ្វើការ *សាងសង់កំពង់ផែ* ដែលត្រូវចំណាយអស់ទឹកប្រាក់សរុបចំនួន៖ **១,៩៥៣,៦៤០ដុល្លារ (មួយលានកៅសិបប្រាំម៉ឺនបីពាន់ប្រាំមួយរយ សែសិបដុល្លារអាមេរិក)** ដូចមានក្នុងកិច្ចសន្យាសាងសង់កំពង់ផែនៃ**សណ្ឋាគារ** [redacted] ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៩។ លុះដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩ សហចុងចម្លើយក៏បានស្នើសុំឱ្យដើមចោទ ធ្វើការសាងសង់បន្ថែមទៀត និងបានចុះកិច្ចសន្យាការងារសាងសង់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩។ ក្នុងកិច្ចសន្យានោះទៀតសោទក៏បានបញ្ជាក់អំពីទំហំការងារ និងរបៀបនៃការបង់ប្រាក់ផងដែរ ដែលត្រូវចំណាយអស់ទឹកប្រាក់សរុបចំនួន៖ **១៥៨,៣០៤ ដុល្លារ (ដប់ប្រាំម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក)** រីឯរបៀបនៃការបង់ប្រាក់វិញគឺបង់តាមដំណាក់កាលដូចមានចែងក្នុងចំណុចទី០៧(ប្រាំពីរ) នៃកិច្ចសន្យាការងារសាងសង់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩។ ក្រោយមកទៀត **ចុងចម្លើយ** ក៏បានឱ្យដើមចោទធ្វើការងារបន្ថែម លើការងារចាស់ដែលមានដូចជាទម្របង្កាន់ដៃ រួមទាំងការតំឡើងបំពង់ដែកជ្រុង ថ្មក្រាលលើទំនប់ និងខ្សែភ្លើង ដែលត្រូវចំណាយអស់ទឹកប្រាក់សរុបចំនួន: **៣៩,៤៨២ដុល្លារ (បីម៉ឺនប្រាំបួនពាន់បួនរយប៉ែតសិបពីរដុល្លារអាមេរិក)** ។ បន្ទាប់ពីចុះកិច្ចសន្យាជាមួយនឹងចុងចម្លើយរួចហើយ ដើមចោទបានអនុវត្តកាតព្វកិច្ច និងសម្រេចនូវរាល់ការងារដូចមានចែងក្នុងកិច្ចសន្យាទាំងអស់រួចរាល់ហើយ។ ផ្ទុយទៅវិញ បែរជាសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចក្នុងការទូទាត់ប្រាក់ជូនដើមចោទគ្រប់ចំនួនតាមកិច្ចសន្យានោះទេ ពោលគឺ ចុងចម្លើយ ទើបតែបានទូទាត់ប្រាក់ជូនដើមចោទចំនួន **$១,៩៩២,៤៣៣.៦២ (មួយលានប្រាំបួនសែនប្រាំបួនម៉ឺនពីរពាន់បួនរយសាមសិបបីដុល្លារអាមេរិកនិងហុកសិបពីរសេន)** តែប៉ុណ្ណោះ ដោយនៅខ្វះចំនួន **$៣៦០,០០០ (សាមសិបប្រាំមួយម៉ឺនដុល្លារអាមេរិក)** ទៀត។ រហូតមកទល់បច្ចុប្បន្ន ទោះបីជាដើមចោទព្យាយាមទាក់ទង ក៏ដូចជាធ្វើការជូនដំណឹងជាច្រើនលើកច្រើនសារ និងស្វែងរកដំណោះស្រាយដោយសន្តិវិធី

យ៉ាងណាក៏ដោយ ក៏**ចុងចម្លើយ** នៅតែមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងកិច្ចសន្យាទាំងអស់ដែលបានចុះជាមួយនឹងដើមចោទឡើយ ដោយតែងតែគេចវេស មិនទទួលខុសត្រូវលើទង្វើរបស់ខ្លួនដែលជាហេតុធ្វើឱ្យដើមចោទ ខូចខាតពេលវេលា និងបាត់បង់ផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ទើបសម្រេចចិត្តដាក់ពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ មកតុលាការតែម្តង ។

**៣.២. ភស្តុតាងថតចម្លងដាក់ដោយដើមចោទ**

- កិច្ចសន្យាការងារសាងសង់ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ។
- តារាងវាយតម្លៃការងារសាងសង់ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ។
- តារាងវាយតម្លៃការងារសាងសង់ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ។
- កិច្ចសន្យាសាងសង់កំពង់ផែនៃ[redacted] ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៩ ។
- តារាងវាយតម្លៃការងារសាងសង់ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៩ ។
- កិច្ចសន្យាការងារសាងសង់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩ ។
- កិច្ចព្រមព្រៀងសន្យា ។
- តារាងវាយតម្លៃការងារសាងសង់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩ ។
- កិច្ចព្រមព្រៀងបន្ថែមនៃកិច្ចសន្យា ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ។
- កិច្ចព្រមព្រៀងបន្ថែមស្តីអំពីកំពង់ផែនៃ[redacted] ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៩ ។

**៤. <u>ការអះអាងរបស់គាគី</u>**

**៤.១** មេធាវី[redacted]និងមេធាវី[redacted]តំណាងដោយអាណត្តិឱ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍៖ ខ្ញុំបាទស្នើសុំកែតម្រូវខ្លឹមសារនៃការទាមទារ ដូចក្នុងពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ និងសុំឱ្យតុលាការមេត្តាចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម៖

១. បង្គាប់អោយសហចុងចម្លើយប្រគល់ប្រាក់ដែលមិនទាន់បានបង់ចំនួន **៣៦០,០០០ដុល្លារ (សាមសិបប្រាំមួយម៉ឺនដុល្លារអាមេរិក)** មកអោយដើមចោទ។

២. បង្គាប់អោយសហចុងចម្លើយសងសំណងជំងឺចិត្ត និងការខាតបង់ពេលវេលា សរុបចំនួន: ៥០០,០០០ដុល្លារ (ហាសិបម៉ឺនដុល្លារអាមេរិក) អោយមកដើមចោទ។

៣. សុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន ត្រង់ចំណុចទី១ ។

៤. បង្គាប់អោយសហចុងចម្លើយជាអ្នកទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តី ។

ខ្ញុំបាទសុំបញ្ជាក់បន្ថែមថា នៅក្នុងអំឡុងឆ្នាំ២០១៩ **ក្រុមហ៊ុន** [redacted] ដែលមានអ្នកតំណាងឈ្មោះ[redacted] CHANGBIN និងឈ្មោះ[redacted] YANRONG ត្រូវជាសហចុងចម្លើយបានទាក់ទងក្រុមហ៊ុនកូនក្តីខ្ញុំបាទឱ្យធ្វើ *ទីលានចុះចតឧទ្ធម្ភាគចក្រ* នៅខាងក្រោយ **សណ្ឋាគារ** [redacted]។ ក្រោយពីបានពិភាក្សាគ្នារួចមក ដើមចោទក៏បានយល់ព្រមទទួលម៉ៅការក្នុងការសាងសង់ទីលានចុះចតឧទ្ធម្ភាគចក្រនោះ ដូចមានក្នុងកិច្ចសន្យាសាងសង់ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។ ក្នុងគម្រោងសាងសង់នោះទៀតសោតគឺ ត្រូវចំណាយអស់ទឹកប្រាក់អស់សរុបចំនួន: **២០១,០០៧.៦២ដុល្លារ (ម្ភៃម៉ឺនមួយពាន់ប្រាំពីរដុល្លារអាមេរិក និងហុកសិបពីរសេន)** ដោយត្រូវបង់ជាដំណាក់កាលមកអោយ



Scanned with CamScanner

ដើមចោទ ដូចមានចែងចំណុចទី០៥(ប្រាំ) នៃកិច្ចសន្យាសាងសង់ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ ក្រោយមក ដោយឃើញពីសមត្ថភាពការងាររបស់ដើមចោទធ្វើបានយ៉ាងល្អប្រសើរ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨ សហចុងចម្លើយ ក៏បានបន្ថែមការងារឱ្យកូនក្តីខ្ញុំបាទមួយទៀត គឺធ្វើការ *សាងសង់កំពង់ផែ* ដែលត្រូវចំណាយអស់ទឹកប្រាក់សរុបចំនួន៖ **១,៩៥៣,៦៤០ដុល្លារ (មួយលានកៅសិបប្រាំម៉ឺនបីពាន់ប្រាំមួយរយ សែសិបដុល្លារអាមេរិក)** ដូចមានក្នុងកិច្ចសន្យាសាងសង់កំពង់ផែនៃ **សណ្ឋាគារ** [redacted] ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨។ លុះដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៨ សហចុងចម្លើយក៏បានស្នើសុំឱ្យកូនក្តីខ្ញុំបាទធ្វើការសាងសង់បន្ថែមទៀត ហើយកូនក្តីខ្ញុំបាទក៏បានយល់ព្រមតាមសំណើររបស់ក្រុមហ៊ុនសហចុងចម្លើយ និងបានចុះកិច្ចសន្យាការងារសាងសង់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៨។ ក្នុងកិច្ចសន្យានោះទៀតសោទក៏បានបញ្ជាក់អំពីទំហំការងារ និងរបៀបនៃការបង់ប្រាក់ផងដែរ។ ពាក់ព័ន្ធជាមួយនឹងទំហំការងារមានដូចជា៖ ចាក់ថ្មលើទំនប់រលកនៅសងខាងឆ្នេរ ចាក់បំពេញឆ្នេរ សំអាតឆ្នេរ ចាក់បំពេញទំនប់ និងចាក់ខ្សាច់បន្ថែម ដែលត្រូវចំណាយអស់ទឹកប្រាក់សរុបចំនួន៖ **$១៥៨,៣០៤ (ដប់ប្រាំម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក)** រីឯរបៀបនៃការបង់ប្រាក់វិញ គឺបង់តាមដំណាក់កាលដូចមានចែងក្នុងចំណុចទី០៧(ប្រាំពីរ) នៃកិច្ចសន្យាការងារសាងសង់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៨។ ក្រោយមកទៀត **សហចុងចម្លើយ** ក៏បានឱ្យកូនក្តីខ្ញុំបាទធ្វើការងាបន្ថែម លើការងារចាស់ដែលមានដូចជាទម្របង្កាន់ដៃ រួមទាំងការតំឡើងបំពង់ដែកជ្រុង ថ្មក្រាលលើទំនប់ និងខ្សែភ្លើង ដែលត្រូវចំណាយអស់ទឹកប្រាក់សរុបចំនួន **៣៩,៤៨២ដុល្លារ (បីម៉ឺនប្រាំបួនពាន់បួនរយប៉ែតសិបពីរដុល្លារអាមេរិក)** ។ បន្ទាប់ពីចុះកិច្ចសន្យាជាមួយនឹង សហចុងចម្លើយ រួចហើយ កូនក្តីខ្ញុំបាទបានអនុវត្តកាតព្វកិច្ច និងសម្រេចនូវរាល់ការងារដូចមានចែងក្នុងកិច្ចសន្យាទាំងអស់រួចរាល់ហើយ។ ផ្ទុយទៅវិញ បែរជាសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចក្នុងការទូទាត់ប្រាក់ជូនកូនក្តីខ្ញុំបាទគ្រប់ចំនួនតាមកិច្ចសន្យានោះទេ ពោលគឺ សហចុងចម្លើយ ទើបតែបានទូទាត់ប្រាក់ជូនកូនក្តីខ្ញុំបាទ ចំនួន **$១,៩៩២,៤៣៣.៦២ (មួយលានប្រាំបួនសែនប្រាំបួនម៉ឺនពីរពាន់បួនរយសាមសិបបីដុល្លារអាមេរិក និងហុកសិបពីរសេន)** តែប៉ុណ្ណោះ ដោយនៅខ្វះទឹកប្រាក់ ចំនួន**:៣៦០,០០០ (សាមសិបប្រាំមួយម៉ឺន)ដុល្លារអាមេរិក** ទៀត។ រហូតមកទល់បច្ចុប្បន្ន ទោះបីជាកូនក្តីខ្ញុំបាទព្យាយាមទាក់ទង ក៏ដូចជាធ្វើការជូនដំណឹងជាច្រើនលើកច្រើនសារ និងស្វែងរកដំណោះស្រាយដោយសន្តិវិធីយ៉ាងណាក៏ដោយ ក៏**សហចុងចម្លើយ** នៅតែមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងកិច្ចសន្យាទាំងអស់ដែលបានចុះជាមួយនឹងខ្ញុំបាទឡើយដោយតែងតែគេចវេស មិនទទួលខុសត្រូវលើទង្វើរបស់ខ្លួន ដែលជាហេតុធ្វើឱ្យកូនក្តីខ្ញុំបាទខូចខាតពេលវេលា និងបាត់បង់ផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរ។ ចំពោះការស្នើសុំកែតម្រូវពាក្យបណ្តឹង ដោយសារតែការទាមទារត្រង់ចំណុចទី១ នៃកម្មវត្ថុនៅក្នុងពាក្យបណ្តឹងរបស់កូនក្តីខ្ញុំបាទ មានការភ័ន្តច្រឡំទៅលើចំនួនទឹកប្រាក់ ដែលត្រូវទាមទារឱ្យសហចុងចម្លើយប្រគល់មកអោយដើមចោទ។ មូលហេតុដែលនាំអោយមានការភ័ន្តច្រឡំទៅលើទឹកប្រាក់នេះ គឺដោយសារតែ កិច្ចព្រមព្រៀងបន្ថែមស្តីពីកំពង់ផែនៃសណ្ឋាគារ [redacted] ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨ នេះគឺ **សណ្ឋាគារ** [redacted] ជាអ្នកមានកាតព្វកិច្ចក្នុងការបង់ប្រាក់ថ្លៃឈ្នួលជូនកូនក្តីខ្ញុំបាទ មិនមែន **ក្រុមហ៊ុន** [redacted] នោះទេ។ ហេតុនេះ ខ្ញុំបាទស្នើសុំដក កិច្ចព្រមព្រៀងបន្ថែមស្តីពីកំពង់ផែនៃសណ្ឋាគារ [redacted] ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨ នេះចេញពីពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ វិញ។ ខ្ញុំបាទ

ស្នើសុំកែតម្រូវពាក្យបណ្តឹងត្រង់ចំណុចទី១ ពី"បង្គាប់អោយសហចុងចម្លើយប្រគល់ប្រាក់ដែលមិនទាន់បានបង់ចំនួន៖ ៦២៨.៤២០$(ហុកសិបពីរម៉ឺនប្រាំបីពាន់បួនរយម្ភៃដុល្លារអាមេរិក)មកអោយដើមចោទ" ទៅជា "បង្គាប់អោយសហចុងចម្លើយប្រគល់ប្រាក់ដែលមិនទាន់បានបង់ចំនួន៖ ៣៦០.០០០$ (សាមសិបប្រាំមួយម៉ឺនដុល្លារអាមេរិក) មកអោយដើមចោទ" វិញ។ ខ្ញុំបាទសុំបញ្ជាក់ផងដែរថា ដូច្នេះ ទឹកប្រាក់ដែលសហចុងចម្លើយបានទូទាត់ជូនកូនក្តីខ្ញុំបាទ គឺមាន ចំនួន **$១,៥៩២,៤៣៣.៦២ (មួយលានប្រាំបួនសែនប្រាំបួនម៉ឺនពីរពាន់បួនរយសាមសិបបី ដុល្លារអាមេរិក និងហុកសិបពីរសេន)** តែប៉ុណ្ណោះ ។

**៤.២.** តុលាការបានធ្វើការកោះហៅសហចុងចម្លើយឈ្មោះ [redacted] CHANGBIN និងឈ្មោះ [redacted] YANRONG ដែលជាអ្នកតំណាងឱ្យ**ក្រុមហ៊ុន** [redacted] ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣ និងបានចេញលិខិតជូនដំណឹងស្តីពីការបញ្ជូនតាមការផ្សាយជាសាធារណៈ (លើកទី២) ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣ និងបានបិទផ្សាយលិខិតជូនដំណឹងនេះ នៅបញ្ជរពត៌មានសាលាដំបូងខេត្តព្រះសីហនុ ព្រមទាំងចុះផ្សាយនៅក្នុងទំព័រហ្វេសប៊ុកផ្លូវការ របស់សាលាដំបូងខេត្តព្រះសីហនុ និងក្នុងសារព័ត៌មាននគរធំ ឆ្នាំទី២៨ លេខ៣១២៧ ចេញផ្សាយថ្ងៃសុក្រ ទី០៣ ខែមីនា ឆ្នាំ២០២៣ ។ ដល់កាលបរិច្ឆេទ សហចុងចម្លើយ អវត្តមាន ដោយគ្មានមូលហេតុ ។

## ៥- ចំណុចវិវាទ និងចំណុចគ្មានវិវាទ

### ៥.១. ចំណុចវិវាទ

- តើការទាមទារឱ្យសហចុងចម្លើយប្រគល់ប្រាក់ចំនួន **៣៦០,០០០ដុល្លារ (សាមសិបប្រាំមួយម៉ឺនដុល្លារអាមេរិក)** មកដើមចោទ មានមូលដ្ឋានត្រឹមត្រូវតាមច្បាប់ដែរឬទេ?

### ៥.២. ចំណុចគ្មានវិវាទ (គ្មាន)

## ៦- <u>សំអាងហេតុ</u>

**-តាមលទ្ធផល នៃការសាកសួរ និងពិនិត្យភស្តុតាង ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ចប់សព្វគ្រប់ឃើញថា៖**

**៦.១.** ផ្អែកតាមពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ បានរំលេចឱ្យឃើញថា ចុងចម្លើយក្រុមហ៊ុន [redacted] មានទីតាំងស្ថិតនៅ [redacted] ដូច្នេះសាលាដំបូងខេត្តព្រះសីហនុ ពិតជាមានសមត្ថកិច្ចទទួល និងវិនិច្ឆ័យបណ្តឹងបាន យោង តាមមាត្រា **៨** នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**៦.២.** យោងតាមកិច្ចសន្យាការងារសាងសង់ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ , កិច្ចសន្យាសាងសង់កំពង់ផែ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៩ និងកិច្ចសន្យាការងារសាងសង់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩ រវាងដើមចោទ និងចុងចម្លើយ ក៏ដូចជាតាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ឃើញថា ដើមចោទ និងចុងចម្លើយ ពិតជាបានចុះកិច្ចសន្យាម៉ៅការ ដោយដើមចោទជាអ្នកសាងសង់ ចំណែកឯចុងចម្លើយជាអ្នកទូទាត់ប្រាក់ ប្រាកដមែន ។ តុលាការគប្បីលើកមកពិចារណា ។



Scanned with CamScanner

៦.៣. អង្គហេតុដែលដើមចោទបានប្តឹងសុំឱ្យចុងចម្លើយប្រគល់ប្រាក់ ដោយបានលើកទឡ្ហីករណ៍ថា ក្នុងអំឡុងឆ្នាំ២០១៩ ចុងចម្លើយបានទាក់ទងដើមចោទឱ្យធ្វើទីលានចុះចតឧទ្ធម្ភាគចក្រ នៅខាងក្រោយសណ្ឋាគារ [redacted]។ ក្រោយពីបានពិភាក្សាគ្នារួចមក ដើមចោទក៏បានយល់ព្រមទទួលម៉ៅការក្នុងការសាងសង់ទីលានចុះចតឧទ្ធម្ភាគចក្រនោះ ដូចមានក្នុងកិច្ចសន្យាសាងសង់ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។ ក្នុងគម្រោងសាងសង់នោះទៀតសោតគឺត្រូវចំណាយអស់ទឹកប្រាក់អស់សរុបចំនួន: **$២០១,០០៧.៦២ (ម្ភៃម៉ឺនមួយពាន់ប្រាំពីរដុល្លារអាមេរិក និងហុកសិបពីរសេន)** ដោយត្រូវបង់ជាដំណាក់កាលមកអោយដើមចោទ ដូចមានចែងចំណុចទី០៧(ប្រាំ) នៃកិច្ចសន្យាសាងសង់ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។ ក្រោយមក ដោយឃើញពីសមត្ថភាពការងាររបស់ដើមចោទ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៩ ចុងចម្លើយ ក៏បានបន្ថែមការងារឱ្យដើមចោទមួយទៀត គឺធ្វើការ *សាងសង់កំពង់ផែ* ដែលត្រូវចំណាយអស់ទឹកប្រាក់សរុបចំនួន៖ **១,៩៥៣,៦៤០ដុល្លារ (មួយលានកៅសិបប្រាំម៉ឺនបីពាន់ប្រាំមួយរយ សែសិបដុល្លារអាមេរិក)** ដូចមានក្នុងកិច្ចសន្យាសាងសង់កំពង់ផែនៃ [redacted] ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៩។ លុះដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩ សហចុងចម្លើយក៏បានស្នើសុំឱ្យដើមចោទ ធ្វើការសាងសង់បន្ថែមទៀត និងបានចុះកិច្ចសន្យាការងារសាងសង់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩។ ក្នុងកិច្ចសន្យានោះទៀតសោទ ក៏បានបញ្ជាក់អំពីទំហំការងារ និងរបៀបនៃការបង់ប្រាក់ផងដែរ ដែលត្រូវចំណាយអស់ទឹកប្រាក់សរុបចំនួន៖ **១៥៨,៣០៤ ដុល្លារ (ដប់ប្រាំម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក)** រីឯរបៀបនៃការបង់ប្រាក់វិញ គឺបង់តាមដំណាក់កាលដូចមានចែងក្នុងចំណុចទី០៧(ប្រាំពីរ) នៃកិច្ចសន្យាការងារសាងសង់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩។ ក្រោយមកទៀត **ចុងចម្លើយ** ក៏បានឱ្យដើមចោទធ្វើការងារបន្ថែម លើការងារចាស់ ដែលមានដូចជាទម្រុបង្កាន់ដៃ រួមទាំងការតំឡើងបំពង់ដែកជ្រុង ថ្មក្រាលលើទំនប់ និងខ្សែភ្លើង ដែលត្រូវចំណាយអស់ទឹកប្រាក់សរុបចំនួន **$៣៩,៤៨២ (បីម៉ឺនប្រាំបួនពាន់បួនរយប៉ែតសិបពីរដុល្លារអាមេរិក)** ។ បន្ទាប់ពីចុះកិច្ចសន្យាជាមួយនឹងចុងចម្លើយរួចហើយ ដើមចោទបានអនុវត្តកាតព្វកិច្ច និងសម្រេចនូវរាល់ការងារ ដូចមានចែងក្នុងកិច្ចសន្យាទាំងអស់រួចរាល់ហើយ។ ផ្ទុយទៅវិញ បែរជាសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចក្នុងការទូទាត់ប្រាក់ជូនដើមចោទគ្រប់ចំនួនតាមកិច្ចសន្យានោះទេ ពោលគឺចុងចម្លើយទើបតែបានទូទាត់ប្រាក់ជូនដើមចោទចំនួន **$១,៩៩២,៤៣៣.៦២ (មួយលានប្រាំបួនសែនប្រាំបួនម៉ឺនពីរពាន់បួនរយសាមសិបបីដុល្លារអាមេរិក និងហុកសិបពីរសេន)** តែប៉ុណ្ណោះ ដោយនៅខ្វះចំនួន **$៣៦០,០០០ (សាមសិបប្រាំមួយម៉ឺនដុល្លារអាមេរិក)** ទៀត។ រហូតមកទល់បច្ចុប្បន្ន ទោះបីជាដើមចោទព្យាយាមទាក់ទង ក៏ដូចជាធ្វើការជូនដំណឹងជាច្រើនលើកច្រើនសារ និងស្វែងរកដំណោះស្រាយដោយសន្តិវិធី យ៉ាងណាក៏ដោយ ក៏**ចុងចម្លើយ** នៅតែមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងកិច្ចសន្យាទាំងអស់ដែលបានចុះជាមួយនឹងដើមចោទឡើយ ដោយតែងតែគេចវេស មិនទទួលខុសត្រូវលើទង្វើរបស់ខ្លួន ដែលជាហេតុធ្វើឱ្យដើមចោទ ខូចខាតពេលវេលា និងបាត់បង់ផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ទើបសម្រេចចិត្តដាក់ពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ មកតុលាការតែម្តង ។ ការអះអាងនេះ អាចឱ្យតុលាការយកមកពិចារណាបាន ។

៦.៤. តុលាការបានធ្វើការកោះហៅសហចុងចម្លើយឈ្មោះ [redacted] CHANGBIN និងឈ្មោះ [redacted] [redacted] RONG ដែលជាអ្នកតំណាងឱ្យ**ក្រុមហ៊ុន** [redacted] ចុះថ្ងៃទី២៩



Scanned with CamScanner

ខែវិច្ឆិកា ឆ្នាំ២០២២ ដោយមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនបានបញ្ជាក់ថា យើងខ្ញុំនាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់លេខ៣ ស្រាវជ្រាវរកឈ្មោះ [redacted] CHANGBIN និងឈ្មោះ [redacted] YANRONG មិនឃើញទេ ហើយយើងខ្ញុំបានចុះទៅដល់ទីតាំង មិនដឹងថា គាត់ទៅរស់នៅទីណាទេ ។ បន្ទាប់មក មេធាវី [redacted] បានដាក់ពាក្យស្នើសុំប្រកាសផ្សាយជាសាធារណៈ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ ស្នើសុំប្រកាសផ្សាយជាសាធារណៈនូវដីកាកោះចំពោះភាគីចុងចម្លើយឈ្មោះ [redacted] CHANGBIN និងឈ្មោះ [redacted] YANRONG ។ ក្រោយមក តុលាការបានសម្រេចចេញដីកាកោះសហចុងចម្លើយឈ្មោះ [redacted] CHANGBIN និងឈ្មោះ [redacted] YANRONG ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ និងបានចេញលិខិតជូនដំណឹងស្តីពីការបញ្ជូនតាមការផ្សាយជាសាធារណៈ (លើកទី១) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ និងបានបិទផ្សាយលិខិតជូនដំណឹងនេះ នៅបញ្ជរពត៌មានសាលាដំបូងខេត្តព្រះសីហនុ ព្រមទាំងចុះផ្សាយនៅក្នុងទំព័រហ្វេសប៊ុកផ្លូវការ របស់សាលាដំបូងខេត្តព្រះសីហនុ និងក្នុងសារព័ត៌មាននគរធំ ឆ្នាំទី២៧ លេខ៣០៧៣ ចេញផ្សាយថ្ងៃសៅរ៍ ទី១៧ ខែធ្នូ ឆ្នាំ២០២២ ដោយកំណត់កាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផល នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង២និង៣០នាទីរសៀល ។ ក្រោយមកទៀត តុលាការបានធ្វើការកោះហៅសហចុងចម្លើយ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣ និងបានចេញលិខិតជូនដំណឹងស្តីពីការបញ្ជូនតាមការផ្សាយជាសាធារណៈ (លើកទី២) ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣ និងបានបិទផ្សាយលិខិតជូនដំណឹងនេះ នៅបញ្ជរពត៌មានសាលាដំបូងខេត្តព្រះសីហនុ ព្រមទាំងចុះផ្សាយនៅក្នុងទំព័រហ្វេសប៊ុកផ្លូវការ របស់សាលាដំបូងខេត្តព្រះសីហនុ និងក្នុងសារព័ត៌មាននគរធំ ឆ្នាំទី២៨ លេខ៣១២៧ ចេញផ្សាយថ្ងៃសុក្រ ទី០៣ ខែមីនា ឆ្នាំ២០២៣ ដោយកំណត់កាលបរិច្ឆេទនីតិវិធីសម្រាប់ការទាញហេតុផលផ្ទាល់មាត់ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ៨ និង៣០នាទីព្រឹក ។ ក្រោយមកទៀត តុលាការបានចេញដីកាកោះហៅ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ និងបានចុះផ្សាយតាមសារព័ត៌មាន នគរធំ ដែលមានឆ្នាំ២៨ លេខ៣១៣៨ ចេញផ្សាយថ្ងៃអង្គារ ទី២១ ខែមីនា ឆ្នាំ២០២៣ ដោយកំណត់កាលបរិច្ឆេទដើម្បីធ្វើការប្រកាសសាលក្រម នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង២និង៣០នាទីរសៀល។ ដោយឡែក នៅគ្រប់នីតិវិធីរបស់តុលាការ សហចុងចម្លើយអវត្តមានដោយគ្មានមូលហេតុ។ តុលាការចាត់ទុកថា សហចុងចម្លើយបានសារភាព តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ស្របតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៦.៥. តុលាការយល់ឃើញថា នៅក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ ដើមចោទបានដាក់ពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ដោយស្នើសុំកែតម្រូវពាក្យបណ្តឹង ដោយសារតែការទាមទារត្រង់ចំណុចទី១ នៃកម្មវត្ថុនៅក្នុងពាក្យបណ្តឹងរបស់ដើមចោទ មានការភ័ន្តច្រឡំទៅលើចំនួនទឹកប្រាក់ ដែលត្រូវទាមទារឱ្យសហចុងចម្លើយប្រគល់មកអោយដើមចោទ។ មូលហេតុដែលនាំអោយមានការភ័ន្តច្រឡំទៅលើទឹកប្រាក់នេះគឺដោយសារតែ កិច្ចព្រមព្រៀងបន្ថែមស្តីពីកំពង់ផែនៃសណ្ឋាគារ [redacted] សត ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៩ នេះគឺ **សណ្ឋាគារ** [redacted] ជាអ្នកមានកាតព្វកិច្ចក្នុងការបង់ប្រាក់ថ្លៃឈ្នួលជូនដើមចោទ មិនមែន **ក្រុមហ៊ុន** [redacted] នោះទេ។ ហេតុនេះ ដើមចោទស្នើសុំដក កិច្ចព្រមព្រៀងបន្ថែមស្តីពីកំពង់ផែនៃសណ្ឋាគារ ស៊ីហ្វូ រីសត ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០១៩ នេះចេញពីពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ វិញ។ ដើមចោទស្នើសុំកែតម្រូវពាក្យ

បណ្ដឹង ត្រង់ចំណុចទី១ ពី "**បង្គាប់អោយសហចុងចម្លើយប្រគល់ប្រាក់ដែលមិនទាន់បានបង់ ចំនួន ៦២៨.៤២០$(ហុកសិបពីរម៉ឺនប្រាំបីពាន់បួនរយម្ភៃដុល្លារអាមេរិក)មកអោយដើមចោទ**" ទៅជា "**បង្គាប់អោយសហចុងចម្លើយប្រគល់ប្រាក់ដែលមិនទាន់បានបង់ចំនួន៖ ៣៦០.០០០$ (សាមសិបប្រាំមួយម៉ឺនដុល្លារអាមេរិក) មកអោយដើមចោទ**" វិញ។ តុលាការយល់ឃើញថា ពាក្យសុំកែតម្រូវពាក្យបណ្ដឹង ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ របស់ដើមចោទ មានមូលហេតុត្រឹមត្រូវ និងមិនមានការប្ដូរមូលដ្ឋាននៃការទាមទារនោះទេ ថែមទាំងមិនធ្វើឱ្យនីតិវិធីនៃបណ្ដឹងមានការយឺតយ៉ាវដែរ ដូច្នេះ តុលាការគប្បីលើកយកមកពិចារណា ស្របតាមបញ្ញត្តិមាត្រា ៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៦.៦. យោងតាមសំអាងហេតុខាងលើ ថា តើការទាមទារឱ្យសហចុងចម្លើយប្រគល់ប្រាក់ចំនួន **$៣៦០,០០០ (សាមសិបប្រាំមួយម៉ឺនដុល្លារអាមេរិក)** មកដើមចោទ មានមូលហេតុត្រឹមត្រូវតាមច្បាប់ដែរឬទេ? ដូច្នេះ ផ្អែកតាមអង្គហេតុ នៃចំណុចវិវាទនេះ តុលាការយល់ឃើញថា ៖

៦.៦.១. ផ្អែកតាមសេចក្ដីថ្លែងការណ៍ របស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទថា កិច្ចសន្យាសាងសង់ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងគម្រោងសាងសង់នេះ គឺត្រូវចំណាយអស់ទឹកប្រាក់អស់សរុបចំនួន **$២០១,០០៧.៦២(ម្ភៃម៉ឺនមួយពាន់ប្រាំពីរដុល្លារអាមេរិក និងហុកសិបពីរសេន)** ដោយត្រូវបង់ជាដំណាក់កាលមកអោយដើមចោទ ដូចមានចែងចំណុចទី០៧(ប្រាំ)នៃកិច្ចសន្យាសាងសង់ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។ ក្រោយមក ដោយឃើញពីសមត្ថភាពការងាររបស់ដើមចោទ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៩ ចុងចម្លើយ ក៏បានបន្ថែមការងារឱ្យដើមចោទមួយទៀត គឺធ្វើការ*សាងសង់កំពង់ផែ*ដែលត្រូវចំណាយអស់ទឹកប្រាក់សរុបចំនួន**១,៩៥៣,៦៤០ ដុល្លារ (មួយលានកៅសិបប្រាំម៉ឺនបីពាន់ប្រាំមួយរយ សែសិបដុល្លារអាមេរិក)** ដូចមានក្នុងកិច្ចសន្យាសាងសង់កំពង់ផែនៃ **សណ្ឋាគារ** [redacted] ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៩។ លុះដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩ សហចុងចម្លើយក៏បានស្នើសុំឱ្យដើមចោទ ធ្វើការសាងសង់បន្ថែមទៀត និងបានចុះកិច្ចសន្យាការងារសាងសង់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩។ ក្នុងកិច្ចសន្យានោះទៀតសោទ ក៏បានបញ្ជាក់អំពីទំហំការងារ និងរបៀបនៃការបង់ប្រាក់ផងដែរ ដែលត្រូវចំណាយអស់ទឹកប្រាក់សរុបចំនួន៖ **១៥៨,៣០៤ ដុល្លារ (ដប់ប្រាំម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក)** រីឯរបៀបនៃការបង់ប្រាក់វិញ គឺបង់តាមដំណាក់កាលដូចមានចែងក្នុងចំណុចទី០៧ (ប្រាំពីរ) នៃកិច្ចសន្យាការងារសាងសង់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩។ ក្រោយមកទៀត **ចុងចម្លើយ** ក៏បានឱ្យដើមចោទធ្វើការងារបន្ថែម លើការងារចាស់ ដែលមានដូចជាទម្រប់ង្កាន់ដៃ រួមទាំងការតំឡើងបំពង់ដែកជ្រុង ថ្មក្រាលលើទំនប់ និងខ្សែភ្លើង ដែលត្រូវចំណាយអស់ទឹកប្រាក់សរុបចំនួន **$៣៩,៤៨២ (បីម៉ឺនប្រាំបួនពាន់បួនរយប៉ែតសិបពីរដុល្លារអាមេរិក)** ។ បន្ទាប់ពីចុះកិច្ចសន្យាជាមួយនឹងចុងចម្លើយរួចហើយ ដើមចោទបានអនុវត្តកាតព្វកិច្ច និងសម្រេចនូវរាល់ការងារដូចមានចែងក្នុងកិច្ចសន្យាទាំងអស់រួចរាល់ហើយ។ ផ្ទុយទៅវិញ បែរជាសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ច ក្នុងការទូទាត់ប្រាក់ជូនដើមចោទគ្រប់ចំនួនតាមកិច្ចសន្យានោះទេ ពោលគឺចុងចម្លើយទើបតែបានទូទាត់ប្រាក់ជូនដើមចោទចំនួន **$១,៩៩២,៤៣៣.៦២ (មួយលានប្រាំបួនសែនប្រាំបួនម៉ឺនពីរពាន់បួនរយសាមសិបបីដុល្លារអាមេរិក និង ហុកសិបពីរសេន)**

តែប៉ុណ្ណោះ ដោយនៅខ្វះចំនួន **$៣៦០,០០០ (សាមសិបប្រាំមួយម៉ឺនដុល្លារអាមេរិក)** ទៀត។ រហូតមកទល់បច្ចុប្បន្ន ទោះបីជាដើមចោទព្យាយាមទាក់ទង ក៏ដូចជាធ្វើការជូនដំណឹងជាច្រើនលើកច្រើនសារ និងស្វែងរកដំណោះស្រាយដោយសន្តិវិធី យ៉ាងណាក៏ដោយក៏**ចុងចម្លើយ** នៅតែមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងកិច្ចសន្យាទាំងអស់ដែលបានចុះជាមួយនឹងដើមចោទឡើយ ដោយតែងតែគេចវេស មិនទទួលខុសត្រូវលើទង្វើរបស់ខ្លួន ដែលជាហេតុធ្វើឱ្យដើមចោទ ខូចខាតពេលវេលា និងបាត់បង់ផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ។ ម្យ៉ាងវិញទៀតសហចុងចម្លើយពុំបានចូលរួមធ្វើវិវាទកម្មគ្រប់នីតិវិធីរបស់តុលាការទេ ដូច្នេះ តុលាការចាត់ទុកថាសហចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ។ ទង្វើរបស់សហចុងចម្លើយបានរំលោភបំពាននឹងកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ តុលាការយល់ឃើញថា ការលើកឡើងនេះអាចឱ្យតុលាការពិចារណាបាន ។

៦.៦.២. ផ្អែកតាមភស្តុតាងដែលភាគីដើមចោទដាក់ក្នុងសំណុំរឿង រួមមាន កិច្ចសន្យាការងារសាងសង់ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ , កិច្ចសន្យាសាងសង់កំពង់ផែ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៩ និងកិច្ចសន្យាការងារសាងសង់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩ , កិច្ចព្រមព្រៀងសន្យា និងកិច្ចព្រមព្រៀងបន្ថែមនៃកិច្ចសន្យា ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ឃើញថា ដើមចោទ និងសហចុងចម្លើយពិតជាបានចុះកិច្ចសន្យាជាមួយគ្នា ប្រាកដមែន ។ ផ្អែកតារាងវាយតម្លៃការងារសាងសង់ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ មានតម្លៃ **$២០១,០០៧.២ (ម្ភៃម៉ឺនមួយពាន់ប្រាំពីរដុល្លារអាមេរិកនិងពីរសេន)**, តារាងវាយតម្លៃការងារសាងសង់ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៩ មានតម្លៃ **$១,៩៥៣,៦៤០(មួយលានកៅសិបប្រាំម៉ឺនបីពាន់ប្រាំមួយរយសែសិបដុល្លារអាមេរិក)** , តារាងវាយតម្លៃការងារសាងសង់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩ មានតម្លៃ **$១៥៨,៣០៤ (ដប់ប្រាំម៉ឺនប្រាំបីពាន់បីរយបួនដុល្លារអាមេរិក)** និងខ្លឹមសារការងារបានបន្ថែម ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ តម្លៃ **$៣៩,៤៨២ (បីម៉ឺនប្រាំបួនពាន់បួនរយប៉ែតសិបពីរដុល្លារអាមេរិក)** សរុបទឹកប្រាក់ចំនួន **$២,៣៥២,៤៣៣.៦២(ពីរលានបីសែនប្រាំម៉ឺនពីរពាន់បួនរយសាមសិបបីដុល្លារអាមេរិក និងហុកសិបពីរសេន)** ។ ដោយផ្អែកតាមការថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានបញ្ជាក់ថា ដើមចោទទទួលបានទឹកប្រាក់ពីសហចុងចម្លើយចំនួន **$១,៩៩២,៤៣៣.៦២ (មួយលានប្រាំបួនសែនប្រាំបួនម៉ឺនពីរពាន់បួនរយសាមសិបបីដុល្លារអាមេរិកនិងហុកសិបពីរសេន)** តែប៉ុណ្ណោះ ដោយនៅខ្វះចំនួន **$៣៦០,០០០ (សាមសិបប្រាំមួយម៉ឺនដុល្លារអាមេរិក)** ទៀត ។ តុលាការយល់ឃើញថា ការអះអាងនេះ មានមូលដ្ឋានអាចឱ្យតុលាការលើកមកពិចារណាបាន ។

៦.៦.៣. ផ្អែកតាមអំនះអំណាងខាងលើ ឃើញថា ភាគីសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យស្របទៅនឹងកិច្ចសន្យាសាងសង់ ដែលកើតចេញពីឆន្ទះរបស់ខ្លួននោះទេ ដែលទង្វើនេះបង្ហាញឱ្យឃើញថាសហចុងចម្លើយពិតជាបានបំពានកិច្ចសន្យាធ្ងន់ធ្ងរ ដែលធ្វើឱ្យដើមចោទបាត់បង់ផលប្រយោជន៍ និង ជាហេតុធ្វើឱ្យកិច្ចសន្យាសាងសង់ខាងលើ ត្រូវបានរំលាយ ស្របតាមបញ្ញត្តិមាត្រា ៤០៧ និងមាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី ។

**៦.៧. អំពីសំណង**

ដើមចោទទាមទារឱ្យសហចុងចម្លើយសងសំណងជំងឺចិត្ត និងការខាតបង់ពេលវេលា សរុបចំនួន **$៥០០,០០០ (ហាសិបម៉ឺនដុល្លារអាមេរិក)**។ តុលាការយល់ឃើញថា ដោយហេតុថាដើមចោទមិនបានដាក់ភស្តុតាងមកតុលាការលើចំណាយផ្សេងៗលើនីតិវិធីមកតុលាការទេ ដូចនេះ តុលាការនឹងធ្វើការសម្រេចតាមតថភាពជាក់ស្តែង ដោយអនុលោមតាមមាត្រា **៤០០** នៃក្រមរដ្ឋប្បវេណី ។

**៦.៨. អំពីការប្រកាសអនុវត្តបណ្តោះអាសន្ន**

ដើមចោទសុំឱ្យតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្ន ត្រង់ចំណុចទី១ ។ តុលាការយល់ឃើញថា ផ្អែកតាមស្មារតីមាត្រា **១៩៦** នៃក្រមនីតិវិធីរដ្ឋប្បវេណី ការប្រកាសឱ្យអនុវត្តបណ្តោះអាសន្នគឺទាក់ទងនឹងសិទ្ធិលើទ្រព្យសម្បត្តិប៉ុណ្ណោះ ដូច្នេះ ពុំមានភាពចាំបាច់ក្នុងការប្រកាស ឱ្យអនុវត្តជាបណ្តោះអាសន្ននោះទេ ។ តុលាការគប្បីសម្រេចច្រានចោលចំណុចនេះ ។

**៦.៩.** ផ្អែកតាមសំអាងហេតុខាងលើ បញ្ជាក់ឱ្យឃើញអំពីអត្ថិភាព នៃអង្គហេតុដែលជាមូលដ្ឋាននៃការទាមទារក្នុងបណ្តឹងរបស់ដើមចោទ តុលាការគប្បីទទួលស្គាល់ការទាមទាររបស់ដើមចោទ ។

**៦.១០.** ចំពោះប្រាក់ប្រដាប់ក្តី គប្បីតុលាការសម្រេចតាមមាត្រា **៦៤ កថាខណ្ឌ១** នៃក្រមនីតិវិធីរដ្ឋប្បវេណី "ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីចាញ់ក្តី ។ ក្នុងករណីដែលបានចាញ់ក្តីតែមួយភាគទេ តុលាការត្រូវសម្រេចនូវបន្ទុកដែលភាគីម្នាក់ៗ ត្រូវទទួលដោយឆន្ទានុសិទ្ធិរបស់ខ្លួន"។

## ៧- <u>**សេចក្តីសម្រេចបញ្ចប់**</u>

**៧.១.** ទទួលស្គាល់ពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ និងពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ របស់ដើមចោទ ប៉ុន្តែច្រានចោលការទាមទារចំណុចទី៣ ។

**៧.២.** បង្គាប់អោយសហចុងចម្លើយប្រគល់ប្រាក់ដែលមិនទាន់បានបង់ចំនួន **$៣៦០,០០០ (សាមសិបប្រាំមួយម៉ឺនដុល្លារអាមេរិក)** មកអោយដើមចោទ។

**៧.៣.** បង្គាប់ឱ្យសហចុងចម្លើយសងសំណងជំងឺចិត្ត និងការខាតបង់ពេលវេលាសរុបចំនួន **៤០.០០០.០០០ (សែសិបលាន)រៀល** មកឱ្យដើមចោទ ការទាមទារលើសពីនេះ ច្រានចោល ។

**៧.៤.** ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

**៧.៥.** ទុកសិទ្ធិឱ្យភាគីប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។/

**ចៅក្រម**

**ហត្ថលេខា និងត្រា:** [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃចន្ទ ៦កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ពស ២៥៦៦

ខេត្តព្រះសីហនុ, ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner